**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គិសនីកម្ពុជា**
**គណៈកម្មាធិការលទ្ធកម្ម**

លេខ:..........PC.អក

**សេចក្តីជូនដំណឹង**
**ស្តីពី**

ការផ្គត់ផ្គង់ វិក្កយបត្រថ្លៃប្រើប្រាស់ថាមពលអគ្គិសនី ចំនួន 17,071,727 សន្លឹក និងវិក្កយបត្រប្រាក់កក់ ចំនួន 100,117 សន្លឹក ជូន សាខាអគ្គិសនីទាំង ០៥ ចំណុះនាយកដ្ឋានអាជីវកម្មចែកចាយ និងអគ្គិសនីខេត្តចំនួន ១៤ សម្រាប់ឆ្នាំ២០២៥.

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា ៖ អគ្គិសនីកម្ពុជា នឹងដាក់ឲ្យដេញថ្លៃជាសាធារណៈដើម្បីផ្គត់ផ្គង់វិក្កយបត្រថ្លៃប្រើប្រាស់ថាមពលអគ្គិសនី ចំនួន 17,071,727 សន្លឹក និងវិក្កយបត្រប្រាក់កក់ ចំនួន 100,117 សន្លឹក ជូន សាខាអគ្គិសនីទាំង ០៥ ចំណុះនាយកដ្ឋានអាជីវកម្មចែកចាយ និងអគ្គិសនីខេត្តចំនួន ១៤ សម្រាប់ឆ្នាំ២០២៥ ។

អគ្គិសនីកម្ពុជា បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មអគ្គិសនីកម្ពុជា ដែលមានអាសយដ្ឋាន: អាគារលេខ២ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញចាប់ពីថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០២៥ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ៖ 092 65 23 57 និង Website: www.edc.com.kh ) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង ១៤:00 ថ្ងៃទី ១០ ខែ មេសា ឆ្នាំ២០២៥ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើវេលាម៉ោង ១៥:00 ថ្ងៃទី ១០ ខែ មេសា ឆ្នាំ២០២៥ ។

ក្រុមហ៊ុន/សហគ្រាសដែលចូលរួមដាក់ឯកសារដេញថ្លៃ ស្នើសុំភ្ជាប់បន្ថែមមកជាមួយនូវឯកសារដេញថ្លៃ ដែលបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម និងភ្ជាប់មកជាមួយនូវ Soft Copy ដែលជាឯកសារ Scan របស់ឯកសារដេញថ្លៃនេះ ។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នាឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃ.......ខែ.......ឆ្នាំ រោង ឆស័ក ព.ស២៥៦៨
រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ២០២៥
**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ហាប់_ទូច**

ចម្លងជូន៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ